**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៩៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ឧ.ព.** ក្នុងគោលបំណងជំរុញនិងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់ គ.ជ.ឧ.ព.

**មាត្រា២ .-**

**គ.ជ.ឧ.ព.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- អនុវត្តនីតិវិធីអនុលោមតាមច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្មនិងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធ
- កំណត់នីតិវិធីរក្សាការសម្ងាត់សម្រាប់ព័ត៌មានដែលបានដាក់ជូន **គ.ជ.ឧ.ព.** ហើយដែលអ្នកផ្តល់ព័ត៌មានបានស្នើសុំរក្សាការសម្ងាត់នៃព័ត៌មាននោះ និងរៀបចំឯកសារផ្ទេរការសម្រាប់បំភ្លឺដល់តុលាការមានសមត្ថកិច្ច ក្នុងករណីមានបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ **គ.ជ.ឧ.ព.**
- ពិនិត្យនិងផ្តល់យោបល់លើទិដ្ឋភាពច្បាប់ទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម
- ពិនិត្យនិងរកវិធីដោះស្រាយក្នុងករណីដែលបទប្បញ្ញត្តិដែលរៀបចំឡើងដោយបញ្ញត្តិករមានសមត្ថកិច្ចណាមួយមានទំនាស់នឹងបទប្បញ្ញត្តិដែលរៀបចំឡើងដោយបញ្ញត្តិករផ្សេងទៀត
- ស្នើសុំរាជរដ្ឋាភិបាលពិនិត្យឬធ្វើវិសោធនកម្មច្បាប់ ឬកែសម្រួលលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលពាក់ព័ន្ធនឹងឧបាស្រ័យពាណិជ្ជកម្ម ក្នុងករណីចាំបាច់
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធទៅនឹងករណីឧបាស្រ័យពាណិជ្ជកម្មនិងការអនុវត្តច្បាប់
- ចូលរួមផ្តល់យោបល់ តាមដាន និងផ្តល់ការគាំទ្រដល់គ្រប់ភាគីពាក់ព័ន្ធ ក្នុងការប្រមូលព័ត៌មាន និងសម្របសម្រួលផ្សេងទៀត ក្នុងករណីព្រះរាជាណាចក្រកម្ពុជាជាកម្មវត្ថុនៃបណ្តឹងឧបាស្រ័យដោយប្រទេសដៃគូ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## សមាសភាពរបស់ គ.ជ.ឧ.ព.

**មាត្រា៣ .-**

**គ.ជ.ឧ.ព.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានពន្ធដារ ១រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| - ប្រធានលេខាធិការដ្ឋាននៃ **គ.ជ.ឧ.ព.** | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ជ.ឧ.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គ.ជ.ឧ.ព.** អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិក ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមនេះត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ភារកិច្ចប្រព្រឹត្តទៅរបស់ គ.ជ.ឧ.ព.

**មាត្រា៤ .-**

**គ.ជ.ឧ.ព.** ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ **គ.ជ.ឧ.ព.** អាចប្រជុំជាវិសាមញ្ញតាមការចាំបាច់។ អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំសាមញ្ញនិងវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន **គ.ជ.ឧ.ព.**។

ក្នុងករណីប្រធាន **គ.ជ.ឧ.ព.** អវត្តមានឬករណីចាំបាច់ ប្រធាន **គ.ជ.ឧ.ព.** អាចប្រគល់សិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានណាម្នាក់ ដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៥ .-**

**គ.ជ.ឧ.ព.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឬមន្ត្រីជំនាញ ចូលរួមប្រជុំតាមការចាំបាច់។

**គ.ជ.ឧ.ព.** អាចអញ្ជើញដៃគូអភិវឌ្ឍ វិស័យឯកជន ទីប្រឹក្សាបច្ចេកទេស ឬជំនាញការជាតិនិងអន្តរជាតិចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា៦ .-**

**គ.ជ.ឧ.ព.** អាចបង្កើតគណៈកម្មការ អនុគណៈកម្មការ ឬក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ឧ.ព.**។

**មាត្រា៧ .-**

សមាសភាព **គ.ជ.ឧ.ព.** អាចត្រូវបានបញ្ចប់ឬផ្លាស់ប្តូរ ក្នុងករណីណាមួយដូចខាងក្រោម៖

ក- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

ខ- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ។

គ- អសមត្ថភាពផ្នែកកាយសម្បទាឬសតិបញ្ញា ដែលពុំអាចបំពេញតួនាទីរបស់ខ្លួនឬទទួលមរណភាព។

**មាត្រា៨ .-**

សមាជិក **គ.ជ.ឧ.ព.** ដែលមានទំនាស់ផលប្រយោជន៍ត្រូវស្ម័គ្រចិត្តដកខ្លួនចេញពីកិច្ចប្រជុំ **គ.ជ.ឧ.ព.**។ ក្នុងករណីសមាជិកមានទំនាស់ផលប្រយោជន៍មិនស្ម័គ្រចិត្តដកខ្លួនចេញពីកិច្ចប្រជុំ **គ.ជ.ឧ.ព.** ត្រូវបោះឆ្នោតសម្រេចបន្ទាប់ពីសាមីខ្លួនបានការពារខ្លួនចំពោះមុខកិច្ចប្រជុំ។ លក្ខខណ្ឌនៃការដកខ្លួនរបស់សមាជិក **គ.ជ.ឧ.ព.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា៩ .-**

**គ.ជ.ឧ.ព.** មាននាយកដ្ឋានផ្តល់ព័ត៌មាននិងផ្ទៀងផ្ទាត់ច្បាប់នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាន។

តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន **គ.ជ.ឧ.ព.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ឧ.ព.**។

**មាត្រា១០ .-**

របៀបរបបការងាររបស់ **គ.ជ.ឧ.ព.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា១១ .-**

**គ.ជ.ឧ.ព.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៥
## ប្រភពធនធានរបស់ គ.ជ.ឧ.ព.

**មាត្រា១២ .-**

**គ.ជ.ឧ.ព.** មានប្រភពធនធានផ្ដត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម។

**គ.ជ.ឧ.ព.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់ប្រភពធនធានស្របច្បាប់ផ្សេងៗតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

ក្រៅពីប្រភពធនធាននិងថវិកាដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើ **គ.ជ.ឧ.ព.** អាចមានប្រភពធនធានផ្សេងទៀតដែលបានមកពីប្រាក់ផាកពិន័យនិងសេវាផ្សេងទៀត ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ